**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តបាត់ដំបង

សំណុំរឿងរដ្ឋប្បវេណីលេខ៖៥៤០/០៥.១០.២០
សញ្ញាណរឿងក្តី៖ ទាមទារប្រាក់
**សាលក្រមលេខ៖ ១៩ "គ"**
**ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២១**

# <u>**គោរពនាមប្រជារាស្ត្រខ្មែរ**</u>

## **សាលាដំបូងខេត្តបាត់ដំបង**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ ដោយមានសមាសភាពចូលរួមដូចខាងក្រោមៈ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តបាត់ដំបង

**ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ៖**

-ដើមចោទឈ្មោះ [redacted] ប៊ុនលី ភេទប្រុស អាយុ៦៦ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] លេន អាយុ៦២ឆ្នាំ ជនជាតិ និងសញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន[redacted]។

-ចុងចម្លើយឈ្មោះ [redacted] ចិន្តា ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិ និងសញ្ជាតិខ្មែរ មានទីលំនៅ[redacted]។

លោកស្រី [redacted] និងលោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ មានការិយាល័យ[redacted]។

*<u>កម្មវត្ថុ:</u> ប្តឹងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖*

១.ទាមទារប្រាក់ដើមចំនួន១៣០០០ (មួយម៉ឺនបីពាន់) ដុល្លារ អាមេរិក ។

២.ទាមទារការប្រាក់ចំនួន ១៨% ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃដែលខកខានបង់។

៣.ទាមទារសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលា ចំនួន១០០០០(មួយម៉ឺន)ដុល្លារអាមេរិក។

៤.សុំប្រកាសឱ្យអនុវត្តបណ្តោះអាសន្នចំណុចទី១។

៥.ទាមទារឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

**អង្គហេតុ និងចំណុចវិវាទ**

១. ការពន្យល់ត្រួសៗអំពីរឿងក្តី

កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ចុងចម្លើយឈ្មោះ ប៉ក់ ចិន្តា បានខ្ចីចងការប្រាក់ចំនួន ១៣០០០ (មួយម៉ឺនបីពាន់)ដុល្លារអាមេរិក និងការប្រាក់៣% ក្នុង១ខែ ស្មើនឹង៣៩០ (បីរយកៅសិប) ដុល្លារអាមេរិក ក្នុង



Scanned with CamScanner

១ខែ ដោយឈ្មោះ [redacted] ចិន្តា បានប្រគល់វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០២០៣០៨០២-១៧០០ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីកម្ម សំណង់ និងសុរិយោដីខេត្តបាត់ដំបង ដើម្បីមកខ្ចីប្រាក់ខ្លួន។ ក្រោយមកឈ្មោះ [redacted] ចិន្តា បាននិយាយថាបើរកប្រាក់សងមិនបានគ្រប់ចំនួនទេ ខ្លួននឹងយល់ព្រមលក់ផ្តាច់នូវអចលនវត្ថុដែលបានតម្កល់ទុកឱ្យខ្លួន។ ចាប់ពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ឈ្មោះ [redacted] ចិន្តា បានឱ្យការប្រាក់រៀងរាល់ខែគឺចំនួន ៣៩០ ដុល្លារអាមេរិក ក្នុងមួយខែ ហើយចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០ ពុំបានឱ្យការប្រាក់ទេ និងចាប់ពីខែមេសា ឆ្នាំ២០២០ រហូតដល់ខែកញ្ញា ឆ្នាំ២០២០ ការប្រាក់យកតែចំនួន ២០០ដុល្លារអាមេរិក ទេក្នុងមួយខែ តែឈ្មោះ [redacted] ចិន្តា គឺពុំបានអនុវត្តសងប្រាក់ទៅតាមកកិច្ចសន្យាឡើយ។ចុងចម្លើយអាក់ខានបង់ការប្រាក់នោះ គឺខ្លួនតែងតែព្យាយាមជាច្រើនលើកដោយឱ្យចុងចម្លើយបង់ការប្រាក់ តែចុងចម្លើយបានគេចវេសម្តងថ្ងៃនេះម្តងថ្ងៃនោះ បើទាក់ទងតាមទូរស័ព្ទក៏លែងទទួលទូរស័ព្ទថែមទៀត។

២. សេចក្តីថ្លែងការណ៍របស់សហដើមចោទ៖

ឈ្មោះ [redacted] ប៊ុនលី និងប្រពន្ធឈ្មោះ [redacted] លេន បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួននៅតែប្តឹងទាមទារឱ្យតុលាការចេញសាលក្រមសម្រេច ទាមទារប្រាក់ដើមចំនួន ១៣០០០(មួយម៉ឺនបីពាន់)ដុល្លារអាមេរិក ,ការប្រាក់១៨%ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃខកខានបង់ ខែឧសភា ឆ្នាំ២០២០ ,សុំទាមទារជម្ងឺចិត្តនិងថ្លៃខាតបង់ពេលវេលាចំនួន ១០០០០ (មួយម៉ឺន)ដុល្លារអាមេរិក ,សុំប្រកាសអនុវត្តជាបណ្តោះអាសន្ននិងឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ចុងចម្លើយឈ្មោះ [redacted] ចិន្តា បានខ្ចីចងការប្រាក់ចំនួន ១៣០០០(មួយម៉ឺនបីពាន់)ដុល្លារអាមេរិក និងបានឱ្យ ការប្រាក់៣%ក្នុងមួយខែ ហើយចុងចម្លើយបានប្រគល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២០៣០៨០២-១៧០០ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ មកដាក់បញ្ចាំខ្លួន ក្រោយមកចុងចម្លើយបាននិយាយថាបើរកប្រាក់មិនបានគ្រប់ចំនួនទេ នឹងសុខចិត្តលក់ផ្តាច់អចលនវត្ថុដែលបានតម្កល់ទុកឱ្យខ្លួនតែម្តងដែលធ្វើឱ្យខ្លួនមានជំនឿទុកចិត្តចំពោះចុងចម្លើយ។ ចាប់ពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ចុងចម្លើយបានបង់ការប្រាក់ជារៀងរាល់ខែគឺចំនួន ៣៩០ (បីកៅសិប)ដុល្លារអាមេរិក ក្នុងមួយខែ ហើយចាប់ពី ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០ ពុំបានឱ្យការប្រាក់មកខ្លួននោះទេ ហើយក្នុងការអាក់ខានបង់ការប្រាក់នេះចុងចម្លើយបានបង់ឱ្យម្តងគឺចំនួន ១.៦០០.០០០(មួយលានហុកសិបម៉ឺន)រៀល ហើយប្រាក់នេះគិតនៅក្នុងខែមេសា ឆ្នាំ២០២០ ហើយចាប់តាំងពីខែឧសភា ឆ្នាំ២០២០ រហូតដល់បច្ចុប្បន្នចុងចម្លើយពុំបានបង់ការប្រាក់មកឱ្យខ្លួនឡើយ។

៣.សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ៖

ឈ្មោះ [redacted] ចិន្តា បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនទទួលស្គាល់ថាខ្លួននៅជំពាក់ប្រាក់ដើមចោទចំនួន ១៣០០០(មួយម៉ឺនបីពាន់)ដុល្លារអាមេរិក ប្រាកដមែន ហើយខ្លួនសុំឱ្យដើមចោទឈប់ទាមទារការប្រាក់

១៨%ក្នុងមួយឆ្នាំ,ទាមទារជម្ងឺចិត្ត និងថ្លៃខាតបង់ពេលវេលាចំនួន១០០០០(មួយម៉ឺន)ដុល្លារអាមេរិក។

**៤.សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយះ**

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការថាះកូនក្តីខ្លួនសុំឱ្យដើមចោទកុំទាមទារយកការប្រាក់នេះដោយសារស្ថានភាពប្រទេសជាតិនិងលើកលែងចំពោះការទាមទារជម្ងឺចិត្តដោយសារស្ថានភាពប្រទេសធ្លាក់ចុះ ។ ចំពោះការប្រាក់៣% ក្នុងមួយខែស្មើនិង៣៦% លើសការប្រាក់ដែលច្បាប់បានកំណត់ ដែលបានបង់ចាប់ពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៦ ដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ សុំឱ្យលោកចៅក្រមសម្រេច ដោយយោងតាមមាត្រា៥៨៥ នៃក្រមរដ្ឋប្បវេណី ខ្លួនស្នើសុំឱ្យលោកចៅក្រមដកការប្រាក់បង់លើសនោះមកកាត់កងជាមួយប្រាក់ដើម។

**៥.អង្គហេតុចំណុចមានវិវាទ និងចំណុចគ្មានវិវាទៈ**

-ចំណុចមានវិវាទៈ ត្រង់ចំណុចទី២ ដល់ចំណុចទី៣ នៃកម្មវត្ថុបណ្តឹងរបស់ភាគីដើមចោទ តើការទាមទាររបស់ភាគីដើមចោទ ត្រង់ចំណុចទី២ ដល់ចំណុចទី៣ មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់អាចឱ្យតុលាការសម្រេចបានដែរឬទេ។

-ចំណុចគ្មានវិវាទៈទាមទារប្រាក់ដើមចំនួន ១៣០០០(មួយម៉ឺនបីពាន់)ដុល្លារអាមេរិក។

## <u>**សំអាងហេតុ**</u>

តាមលទ្ធផលនៃការសាកសួរគូភាគី និងពិនិត្យភស្តុតាងនៅក្នុងនីតិវិធីនេះឃើញថាះ

១.តាមការអះអាងរបស់គូភាគីបញ្ជាក់ថា ដើមចោទ និងចុងចម្លើយពិតជាបានព្រមព្រៀងគ្នា ចុះកិច្ចសន្យាខ្ចីចងការប្រាក់ និងដាក់អចលនវត្ថុធានាសងបំណុល ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ប្រាកដមែន។ ដូច្នេះតុលាការយល់ឃើញថា ពិតជាមានអង្គហេតុខ្ចីប្រាក់ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ពិតប្រាកដមែន។

២.ភាគីដើមចោទប្តឹងទាមទារប្រាក់ដើមចំនួន ១៣០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ដោយខ្លួនសំអាងលើកិច្ចសន្យាខ្ចីចងការប្រាក់ និងដាក់អចលនវត្ថុធានាសងបំណុល និងកិច្ចសន្យាបង្កើតសិទ្ធិដាក់បញ្ចាំ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ដែលមានទឹកប្រាក់ចំនួន ១៣០០០(មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ដែលបញ្ជាក់ថាភាគីចុងចម្លើយជំពាក់ប្រាក់ខ្លួនពិតប្រាកដមែន ហើយពុំបានសងខ្លួនតាមពេលកំណត់។ ដូច្នេះគប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទតាមបញ្ញត្តិមាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណី។

៣.តាមការពិនិត្យវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០២០៣០៨០២-១៧០០ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ឃើញថា អចលនវត្ថុ ដែលមានឈ្មោះ [redacted] ចិន្តា និងប្តីឈ្មោះ [redacted] រិទ្ធី ជាម្ចាស់កម្មសិទ្ធិ ដែលបានដាក់បញ្ចាំ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ រវាងឈ្មោះ [redacted] ប៊ុនលី និងប្រពន្ធឈ្មោះ [redacted] លេន និងឈ្មោះ [redacted] ចិន្តា ពិតប្រាកដមែន។

៤.នៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ មេធាវីតំណាងដោយអាណត្តិឱ្យភាគីចុងចម្លើយ កូនក្តីខ្លួនទទួលស្គាល់ការជំពាក់ប្រាក់ចំនួន ១៣០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក , ឈប់ឱ្យដើមចោទទាមទារការប្រាក់ចំនួន ១៨ ភាគរយ ក្នុងមួយឆ្នាំ និងឈប់ទាមទារជម្ងឺចិត្ត និងថ្លៃខាតបង់ពេលវេលាចំនួន ១០០០០(មួយម៉ឺន)ដុល្លារអាមេរិក។ហេតុដូច្នេះតុលាការនឹងធ្វើការពិចារណា និងសម្រេចតាមច្បាប់។

៥.តាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ បានបញ្ជាក់ ឱ្យឃើញថា ដើមចោទ និងចុងចម្លើយពិតជាបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគ ដែលមានអត្រាការប្រាក់ ៣% ក្នុងមួយខែ គឺស្មើនិង៣៩០ (បីរយកៅសិប)ដុល្លារអាមេរិក លើប្រាក់ដើមចំនួន ១៣០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក។ដូច្នេះគប្បីតុលាការសម្រេចអំពីការប្រាក់តាមបញ្ញត្តិមាត្រា ៥៩១ មាត្រា ៥៨៤ នៃក្រមរដ្ឋប្បវេណី



Scanned with CamScanner

និងមាត្រា១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រកាសលេខ ១២៨ កយ.ប្រក/ ១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌។

៦.ដើមចោទបានទាមទារឱ្យភាគីចុងចម្លើយបង់សំណាង់ជម្ងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ១០០០០០ (មួយម៉ឺន)ដុល្លារអាមេរិក ចំណុចនេះតុលាការគប្បីពិចារណា និងសម្រេចឱ្យខ្លះៗ ស្របទៅតាមមាត្រា ៤០០ មាត្រា៤០១ នៃក្រមរដ្ឋប្បវេណី។

៧.ភាគីដើមចោទបានស្នើសុំប្រកាសអនុវត្តបណ្តោះអាសន្ន មានភាពសមរម្យស្របតាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីពិចារណាសម្រេចតាមការស្នើសុំនេះ។

៨.ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ចិន្តា សងប្រាក់ដើមចំនួន ១៣០០០(មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ទៅ ឱ្យភាគីដើមចោទឈ្មោះ [redacted] ប៊ុនលី និងប្រពន្ធឈ្មោះ [redacted] លេន ។

២.បង្គាប់ឱ្យភាគីចុងចម្លើយឈ្មោះ [redacted] ចិន្តា បង់ការប្រាក់ចំនួន១៨% ក្នុងឆ្នាំ លើប្រាក់ដើមចំនួន ១៣០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួនទៅឱ្យភាគីដើមចោទ។

៣.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ចិន្តា បង់សំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាជាប្រាក់ចំនួន ២០០០(ពីរពាន់)ដុល្លារអាមេរិក ទៅឱ្យដើមចោទឈ្មោះ [redacted] ប៊ុនលី និងប្រពន្ធឈ្មោះ [redacted] លេន ។ រីឯការទាមទារលើសពីនេះត្រូវច្រានចោល។

៤.ចុងចម្លើយឈ្មោះ [redacted] ចិន្តា ទាមទារផ្សេងៗទៀត ត្រូវច្រានចោល។

៥.សាលក្រមនេះប្រកាសអនុវត្តបណ្តោះអាសន្នត្រង់ចំណុចទី១ នៃសេចក្តីសម្រេចបញ្ចប់។

៦.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ ។

ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល០១ (មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ខេត្តបាត់ដំបង,ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១

**ចៅក្រម**

**ហត្ថលេខា និងត្រា**

[redacted]

---

បានឃើញ

**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ខេត្តបាត់ដំបង,ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner